# ហេតុអ្វីបានជាបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) មានសារៈសំខាន់?

ខណៈពេលដែលប្រព័ន្ធហិរញ្ញវត្ថុគឺជាសរសៃឈាមសេដ្ឋកិច្ច និងជាដៃគូដែលមិនអាចខ្វះបានសម្រាប់សកម្មភាពសេដ្ឋកិច្ចជាទូទៅគួបផ្សំនឹងការមកដល់នៃបច្ចេកវិទ្យាឌីជីថលផងដែរនោះ «**បច្ចេកវិទ្យាហិរញ្ញវត្ថុ**» បាននឹងកំពុងដើរតួយ៉ាងសំខាន់ក្នុងការបង្កើនប្រសិទ្ធភាពប្រតិបត្តិការហិរញ្ញវត្ថុ កាត់បន្ថយការចំណាយ ចូលរួមឆ្លើយតបចំពោះការវិវត្តនៃសកម្មភាពសេដ្ឋកិច្ចសម័យឌីជីថល ការប្រែប្រួលឥតឈប់ឈរនៃតម្រូវការ និងចំណង់ចំណូលចិត្តនៅក្នុងសង្គម។



# ភាពងាយស្រួល

យើងសង្កេតឃើញថា ការផ្ទេរប្រាក់តាមប្រព័ន្ធធនាគារជាលក្ខណៈប្រពៃណីហាក់មានភាពស្មុគស្មាញ ដែលទាមទារឱ្យមានការបំពេញទម្រង់បែបបទច្រើន និងមិនមានសេវាគ្របដណ្តប់ដល់គ្រប់ទីកន្លែងនោះទេ។ ជាមួយគ្នានេះផងដែរ ការកើនឡើងនៃការប្រើប្រាស់ទូរស័ព្ទចល័ត និងឧបករណ៍វៃឆ្លាតបានផ្តល់ឱកាសដល់ក្រុមហ៊ុនបច្ចេកវិទ្យាក្នុងការផ្តល់សេវាកម្មផ្ទេរ និងទូទាត់ប្រាក់តាមរយៈឧបករណ៍វៃឆ្លាតទាំងនោះដោយប្រើប្រាស់ត្រឹមតែកម្មវិធីនៅលើទូរស័ព្ទប៉ុណ្ណោះ។ អ្នកប្រើប្រាស់អាចទូទាត់ ឬផ្ទេរសាច់ប្រាក់បានទៅគ្រប់ទីកន្លែង ដោយមានភាពងាយស្រួល រហ័សជាងមុន និងចំណេញពេលវេលា។



# កាត់បន្ថយការចំណាយ

ការផ្ទេរប្រាក់តាមប្រព័ន្ធធនាគារជាលក្ខណៈប្រពៃណីក្រៅពីមានភាពស្មុគស្មាញហើយ នោះកម្រៃសេវាកម្មទៀតសោតក៏មានតម្លៃខ្ពស់ផងដែរ។ បច្ចេកវិទ្យាហិរញ្ញវត្ថុបានដើរតួជាដំណោះស្រាយយ៉ាងសំខាន់ក្នុងការកាត់បន្ថយការចំណាយលើប្រតិបត្តិការហិរញ្ញវត្ថុ ដោយកម្រៃប្រតិបត្តិការ ឬសេវាកម្មមានតម្លៃទាប ឬមិនអស់កម្រៃតែម្តង។

បច្ចុប្បន្ននេះ ធនាគារភាគច្រើនក៏បានចាប់យកបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយអនុញ្ញាតឱ្យអតិថិជនអាចធ្វើការផ្ទេរប្រាក់ពីគណនីមួយទៅគណនីមួយផ្សេងទៀតនៅក្នុងធនាគារតែមួយដោយមិនអស់កម្រៃ និងឈានទៅការផ្ទេរប្រាក់ឆ្លងធនាគារក្នុងចំនួនកំណត់ណាមួយដោយមិនអស់កម្រៃទៀតផង។



# សុវត្ថិភាព

បច្ចេកវិទ្យាហិរញ្ញវត្ថុត្រូវបានបង្កើតឡើងដោយផ្តោតសំខាន់ទៅលើសុវត្ថិភាពហិរញ្ញវត្ថុ ដោយរក្សាទុកទិន្នន័យអតិថិជនប្រកបដោយសុវត្ថិភាពបំផុត។ ចំពោះអ្នកប្រើប្រាស់ការទូទាត់ ឬផ្ទេរប្រាក់ដោយប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុអាចជួយពួកគេឱ្យចៀសផុតពីការឆក់ ឬប្លន់នៅក្នុងអំឡុងពេលដែលពួកគេប្រើប្រាស់សាច់ប្រាក់ផ្ទាល់។ លើសពីនេះទៀត អ្នកប្រើប្រាស់នៅតែអាចរក្សាបាននូវសាច់ប្រាក់របស់ពួកគេ បើទោះបីជាបាត់បង់ទូរស័ព្ទក៏ដោយ។

